**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០១៥/១០/២០០៨ កបធ.សជណ                    រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៨

**ជម្រាបមក**

**លោក គង់ សំអុន**

មេធាវីគណបក្ស សម រង្ស៊ី តំណាងឱ្យលោក ជា ជីវ

**កម្មវត្ថុ** : រឿងទាក់ទងនឹងបណ្ដឹងរបស់លោកមេធាវី គង់ សំអុន ប្ដឹងតវ៉ាសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមលិខិតលេខ ៩៧៨/០៨ គ.ជ.ប ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០០៨ និង លិខិតលេខ ៩៨០/០៨ គ.ជ.ប ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០០៨

**យោង** : បណ្ដឹងគ្មានលេខ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០០៨ របស់លោកមេធាវី គង់ សំអុន តំណាងឱ្យលោក ជា ជីវ តំណាងគណបក្ស សម រង្ស៊ី ខេត្តបាត់ដំបង

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបមក លោកមេធាវី គង់ សំអុន ជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៨ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យលើបណ្ដឹងរបស់លោករួចហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា ពុំអាចលើកយកបណ្ដឹងនេះមកពិភាក្សា និង សម្រេចបានឡើយ ពីព្រោះបណ្ដឹងរបស់លោកមិនចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានចែងក្នុងមាត្រា ២៥ថ្មី មាត្រា ២៦ និង មាត្រា ២៧ថ្មី នៃច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និង មាត្រា ៧៣ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នោះទេ ។

សូមលោកទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**